# ចំណាប់អារម្មណ៍របស់
# លោកស្រី ជឹម ម៉ាណាវ នាយិកាប្រតិបត្តិ អង្គការវិទ្យាស្ថានបើកទូលាយ
# ក្នុងវេទិកាពិភាក្សាពី " ក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី និងការទទួលព័ត៌មាន "
# ភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១២

---------

សូមគោរព លោកស្រី អស់លោក និងប្អូនៗដែលមានវត្តមាននាពេលនេះ!

ថ្ងៃនេះអង្គការវិទ្យាស្ថានបើកទូលាយមានកិត្តិយស និងមានសេចក្ដីសោមនស្សរីករាយដោយបានទទួល អស់លោក លោកស្រីក្នុងកិច្ចប្រជុំនេះ។ វេទិកាពិភាក្សាពី " **ក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី និងការទទួលព័ត៌មាន**" សហការរៀបចំដោយសម្ព័ន្ធ ភាពជាតិឃុំ សង្កាត់ និងអង្គការវិទ្យាស្ថានបើកទូលាយ។ តាងនាមអ្នករៀបចំកម្មវិធី នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកស្រី អស់លោក ដែលបានឆ្លៀតពេលមាញឹកអញ្ជើញមកចូលរួមក្នុងវេទិកាពិភាក្សាថ្ងៃនេះ។

ជាមួយគ្នានេះ យើងទាំងអស់គ្នាក៏មានទុក្ខក្រៀមក្រំដោយសម្ដេចឪ ព្រះករុណា សម្ដេចព្រះនរោត្តមសីហនុបានយាងចូលព្រះទិវង្គតក្នុងព្រះជន្មាយុ៩០ព្រះវស្សា។ នេះគឺជាការបាត់បង់ដ៏ធំធេងមួយ របស់ប្រជាពលរដ្ឋខ្មែរ ដែលបានបាត់បង់អតីតព្រះមហាក្សត្រមួយអង្គ ដែលនៅក្នុងឆាកព្រះជន្មរបស់ព្រះមហាក្សត្រ ទ្រង់បានខិតខំប្រឹងប្រែងបង្កើតឲ្យមានឯករាជ្យភាព ការការពារបូរណភាពទឹកដី ការបង្រួបបង្រួមជាតិ និងនាំមកសន្តិភាពដល់ប្រទេសជាតិ។ រាជរដ្ឋាភិបាលក៏បានប្រកាសឲ្យពលរដ្ឋកម្ពុជាទូទាំងប្រទេសចូលរួមកាន់ទុក្ខថ្វាយព្រះបរមសពរបស់សម្ដេចឪ នរោត្តម សីហនុ ។ នាងខ្ញុំសូមអញ្ជើញយើងទាំងអស់គ្នាស្ងិងស្ងាត់មួយនាទីលំអោនកាយគោរពដល់ព្រះបរមសពរបស់សម្ដេចឪ និងសូមឲ្យព្រះវិញ្ញាណក្ខន្ធរបស់ព្រះអង្គបានទៅកាន់សុគតិភព។

លោកស្រី អស់លោក ជាទីគោរពនិងប្អូនៗ ជាទីមេត្រី!

*គោលបំណងរបស់វេទិកាពិភាក្សា៖*

- ផ្ដល់ឱកាសដល់ក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រីចែករំលែកនូវបទពិសោធន៍និងឧបសគ្គអំពីការ

ទទួលព័ត៌មានទាក់ទងនិងការងាររបស់ពួកគាត់

- កំណត់យុទ្ធសាស្ត្រនានាដើម្បីជំរុញការទទួលព័ត៌មានកាន់តែប្រសើរសម្រាប់ក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី

លោកស្រីអស់លោក ជាទីគោរព!

ដូចលោកស្រី អស់លោក បានជ្រាបហើយថា សិទ្ធិក្នុងការចូលទៅកាន់ព័ត៌មានផ្តល់ឲ្យប្រជាពលរដ្ឋនូវសិទ្ធិស្របច្បាប់មួយក្នុងការទទួលព័ត៌មានគ្រប់គ្រងដោយរដ្ឋាភិបាល ពាក់ព័ន្ធសេវាសាធារណៈ ឬ ពាក់ព័ន្ធវិស័យឯកជន។ ការចូលទៅកាន់ព័ត៌មាន គឺមានសារសំខាន់ណាស់សម្រាប់អភិបាលកិច្ចតាមរបៀបប្រជាធិបតេយ្យ ការចូលរួមពីសាធារណជន ការអភិវឌ្ឍសេដ្ឋកិច្ច ការការពារសិទ្ធិមនុស្ស ការជំរុញសេរីភាពព័ត៌មាន និងតម្លាភាព។ល។

ការចូលទៅកាន់ព័ត៌មានគឺជាផ្នែកមួយនៃសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ដែលត្រូវបានទទួលស្គាល់ជាសិទ្ធិជាមូលដ្ឋានរបស់មនុស្ស ទទួលស្គាល់ដោយសេចក្តីសម្រេចចិត្តលេខ៥៩ អនុមតិដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីឆ្នាំ១៩៤៦។ សិទ្ធិក្នុងការចូលទៅកាន់ព័ត៌មានក៏ដូចជាសិទ្ធិក្នុងការបញ្ចេញមតិយោបល់មានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលប្រទេសកម្ពុជាបានគាំទ្រ ( Universal Declaration of Human Rights )មាត្រា១៩ "មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពមានមតិ និងសេរីភាពក្នុងការសម្តែងមតិ។ សិទ្ធិនេះរាប់ទាំងសេរីភាពក្នុងការប្រកាន់មតិ និងការសម្តែងមតិ ដោយគ្មានការជ្រៀតជ្រែក ព្រមទាំងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា តាមរយៈប្រព័ន្ធឃោសនាណាមួយក៏ដោយ និងដោយឥតគិតពីព្រំដែនអ្វីឡើយ ។"

ច្បាប់និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏បានការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ពិសេសសិទ្ធិក្នុងការចូលទៅកាន់ព័ត៌មានក៏ដូចជាសិទ្ធិក្នុងការបញ្ចេញមតិយោបល់។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៣១បានចែងថា " ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ "

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញបានចែងថា " ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និង ដល់សន្តិសុខជាតិបានឡើយ។ របប

សារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់។ "

ទោះជាយ៉ាងដូច្នេះក្តី យើងសង្កេតឃើញថា ការទទួលព័ត៌មានរបស់ប្រជាពលរដ្ឋនៅមានកម្រិតអាស្រ័យដោយការចែកចាយ និងមធ្យោបាយនៃការចែកចាយនៅមានកម្រិត និងដោយសារវប្បធម៌ចែកចាយព័ត៌មានសាធារណៈមិនទាន់មានលក្ខណៈបើកចំហនៅឡើយ។ ទោះបីជាមានការរីកចម្រើន ស្ត្រីនៅតែប្រឈមនឹងឧបសគ្គនានាដែលរារាំងដល់ការចូលរួមក្នុងនយោបាយរបស់ពួកគេ។ ឧបសគ្គទាំងនេះរួមមានបទដ្ឋានវប្បធម៌ និង សង្គម ផ្នត់គំនិតសង្គមពីបុរាណ កង្វះខាតនៃការគាំទ្រពីក្រុមគ្រួសារ មិត្តភក្តិ និង មិត្តរួមការងារ កង្វះខាតឱកាសនៃការអប់រំ និង បណ្តុះបណ្តាល កង្វះចំណេះដឹងផ្នែកនយោបាយ និងទំនុកចិត្ត ភាពជឿជាក់និងជំនាញសមស្របនៅមានកម្រិត ។ ស្ត្រីកម្ពុជាភាគច្រើនមានឱកាសតិចតួចក្នុងការទទួលបាននូវព័ត៌មាន និងសំខាន់ជាងនេះទៀតគឺកង្វះខាតនៃយល់ដឹងពីសិទ្ធិរបស់គាត់ក្នុងការទទួលនិងផ្សព្វផ្សាយព័ត៌មានបើប្រៀបធៀបជាមួយបុរស។

ឧបសគ្គទាំងនេះបានប៉ះពាល់ដល់ការងារប្រចាំថ្ងៃរបស់ស្ត្រី ដូចជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រីដែលបំពេញការងារជាច្រើននៅក្នុងការងារសាធារណៈ។ នេះជាឧបសគ្គធំសម្រាប់ពួកគាត់បំពេញការងាររបស់ពួកគាត់ដែលជាមន្ត្រីទទួលបន្ទុកព័ត៌មានសាធារណៈ ឬម្ចាស់ព័ត៌មានសាធារណៈ និងគាត់ជាបុគ្គលដែលត្រូវការទទួលព័ត៌មានសាធារណៈច្រើនដើម្បីបម្រើសេវាកម្មសាធារណៈនិងអត្ថប្រយោជន៍សាធារណៈអោយបានប្រសើរឡើង។

ការចូលទៅកាន់ ព័ត៌មានបានបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការបញ្ចេញ និងអនុវត្តសំឡេងរបស់ខ្លួន និងការតាមដានគណនេយ្យភាពរបស់រដ្ឋាភិបាលក៏ដូចជាការចូលរួមយ៉ាងពេញលេញនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ដល់ជីវិតរស់នៅរបស់គេ។ នៅក្នុងសម័យICT ស្ត្រីអាចប្រើប្រាស់ព័ត៌មានសម្រាប់ការស្វែងរកការគាំទ្រ និងបង្កើតនូវការផ្សព្វផ្សាយព័ត៌មាននៅក្នុងសហគមន៍របស់ពួកគេដូចជាយុទ្ធនាការទប់ស្កាត់អំពើហិង្សាយេនឌ័រត្រូវបានលើកកម្ពស់តាមរយៈនៃការប្រើប្រាស់ICT និងតាមរយៈនៃការចូលទៅកាន់ព័ត៌មានពាក់ព័ន្ធ ជាដើម។

ការចូលទៅកាន់ព័ត៌មានបានជួយដល់សហគមន៍ដែលងាយរងគ្រោះអាចធ្វើសមាហរណកម្មចូលទៅក្នុងសង្គមបាន។ ការចូលទៅកាន់ព័ត៌មានក៏បានធ្វើឲ្យការយល់ដឹងរបស់ស្ត្រីអំពី សិទ្ធិពលរដ្ឋ និងការទទួលខុសត្រូវរបស់ពួកគេមានការកើនឡើង ក៏ដូចជាការកើនឡើងនៃការប្រមូលផ្តុំស្ត្រីដែលមានចំណេះដឹង ដែលអាចចូលរួមនៅក្នុងដំណើរការបោះឆ្នោត មានដូចជាការទៅបោះឆ្នោត និង ការឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យ។ ការចូលទៅកាន់ព័ត៌មាននឹងធ្វើឲ្យមានការកើនឡើងចំនួនស្ត្រីក្នុងតួនាទីជាអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យសាធារណៈ និងឯកជន ។ ជាងនេះទៅទៀតការចូលទៅកាន់ព័ត៌មាន ក៏ធ្វើឲ្យសហគមន៍អាចគ្រប់គ្រងបាននូវដំណើរការបោះឆ្នោតដើម្បីជំរុញគណនេយ្យ

ភាព តម្លាភាព និង អភិបាលកិច្ចល្អ។

ថ្ងៃនេះយើងនឹងពិភាក្សាអំពីបញ្ហានេះ អំពីគម្លាតរវាងច្បាប់និងការអនុវត្តច្បាប់ និងអំពីផលប៉ះពាល់ដល់ប្រជាពលរដ្ឋ ដល់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ជា ពិសេស ក្រុមប្រឹក្សាឃុំ/សង្កាត់ជាស្ត្រីដែលការទទួលព័ត៌មានរបស់ពួកគាត់នៅមានកម្រិតបើប្រៀបធៀបជាមួយសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ដែលជាបុរស។

យើងសង្ឃឹមថា កិច្ចពិភាក្សាថ្ងៃនេះ នឹងរកឃើញនូវគន្លឹះ ក្នុងការផ្សព្វផ្សាយព័ត៌មានសាធារណៈឲ្យបានច្រើនជាង និងបើកចំហជាងជាប្រយោជន៍ដល់ប្រជាពលរដ្ឋ ជាពិសេសដល់សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ជាស្ត្រីសម្រាប់ការអនុវត្តភារកិច្ចឲ្យមានប្រសិទ្ធភាពប្រសើរជាងមុន។

មុននិងបញ្ចប់ នាងខ្ញុំសូមជូនពរ លោកជំទាវ អស់លោក លោកស្រីដែលមានវត្តមាននាពេលនេះ សូមប្រកបដោយសុខភាពបរិបូរណ៍ បញ្ញាវាងវៃ និងទទួលបានជោគជ័យក្នុងរាល់ការងារ។

សូមអរគុណ